**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**
**អំពើជួញដូរមនុស្ស**

លេខ ០៧៥/២៣ .....រ.ប.ក

# របាយការណ៍ខែកុម្ភៈ
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងទិសដៅខែមីនា ឆ្នាំ២០២៣

## I. ស្ថានភាពទូទៅ

ក្រសួង ស្ថាប័ន រាជធានី ខេត្ត នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបន្តសកម្មភាព របស់ខ្លួនទៅតាមទិសដៅគ្រោងទុក បើទោះប្រទេសជាតិ បាន និងកំពុងតែប្រឈមនឹងសភាពការណ៍វិវត្តន៍ថ្មី ដែលមិនអាចប៉ាន់ស្មានបាន ពាក់ព័ន្ធនឹងការជះឥទ្ធិពលពីការប្រែប្រួលនៃសភាពការណ៍ពិភពលោក ដែលមានទាំងវិបត្តិសេដ្ឋកិច្ច សង្គ្រាមរ៉ាំរ៉ៃនៅបណ្តាប្រទេសមួយចំនួន គ្រោះធម្មជាតិ( ទឹកជំនន់ ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ បំណាក់ដី ភ្លើងឆេះព្រៃ...) និងថែមទាំងគ្រោះមហន្តរាយដោយការរាតត្បាតដោយវីរុសកូវីដ-១៩ និងមេរោគបម្លែងថ្មី។

ក្រោយពីពិភពលោកកំពុងតែប្រយុទ្ធប្រឆាំងនឹងវិបត្តិជំងឺកូវីដ-១៩ មិនទាន់បានចប់ផង ក៏មានព្រឹត្តិការណ៍ថ្មីមួយទៀត ចាប់ពីខែ កុម្ភៈ ឆ្នាំ២០២២ មកដល់ពេលបច្ចុប្បន្ននេះមានការផ្ទុះសង្គ្រាមរវាងប្រទេសរុស្សី និងប្រទេសអ៊ុយក្រែន បានបង្កឱ្យមានវិបត្តិសេដ្ឋកិច្ចទូទាំងសកលលោក ដូចជាប្រេង និងឧស្ម័ន បានឡើងថ្លៃខ្ពស់ រហូតធ្វើឱ្យប្រទេសមួយចំនួនមានសេដ្ឋកិច្ចធ្លាក់ចុះយ៉ាងខ្លាំង និងមានវិបត្តិជំពាក់បំណាល់គេដ៏ធ្ងន់ធ្ងរ ដែលមិនអាចដោះស្រាយបាន។

រាជរដ្ឋាភិបាលយើងបាន និងកំពុងតែ យកចិត្តទុកដាក់យ៉ាងខ្លាំង លើកិច្ចការពារអាយុជីវិតប្រជាពលរដ្ឋ ដែលបង្កដោយការរាតត្បាតដ៏ខ្លាំងក្លានៃវីរុសកូវីដ-១៩ និងផលប៉ះពាល់ដ៏ធំធេងលើ ជីវភាព និងសុខភាពប្រជាពលរដ្ឋ ព្រមទាំងសេដ្ឋកិច្ចសង្គមយ៉ាងធ្ងន់ធ្ងរ ជាភាពប្រឈមថ្មី និងដែលជះឥទ្ធិពលដល់ការអនុវត្តសកម្មភាពគ្រប់វិស័យ ធ្វើឱ្យរាំងស្ទះដោយអន្លើ នូវផែនការសកម្មភាពនានា ដែលបានគ្រោងទុក និងត្រូវបន្ថែមភារកិច្ចក្នុងការដោះស្រាយ ទប់ស្កាត់ផលប៉ះពាល់ លើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ចំណែកឯប្រជាជនយើង មួយចំនួននៅតែមើលស្រាលស្ថានភាព មិនស្តាប់ការអប់រំណែនាំ មិនតាមដានព័ត៌មានដែលមានប្រយោជន៍ តែបែរជាស្តាប់ និងជឿការអូសទាញ ភូតភរពីមេខ្យល់ ធ្វើឱ្យពួកគាត់ធ្លាក់ទៅក្នុងអំពើជួញដូរមនុស្ស និងខាតបង់ទាំងទ្រព្យសម្បត្តិ និងកម្លាំងកាយ រហូតដល់ធ្លាក់ខ្លួនឈឺដ៏ធ្ងន់ធ្ងរថែមទៀត។

អាជ្ញាធរ សមត្ថកិច្ច និងលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ និងអង្គការដៃគូ បានធ្វើសកម្មភាពយ៉ាងមមាញឹក ប្រចាំការនៅតាមព្រំដែនទទួលសង្គ្រោះពលករ ដែលវិលត្រឡប់តាមច្រកមិនផ្លូវការ ទាំងយប់ទាំងថ្ងៃ ពិនិត្យកម្តៅ និងផ្តល់សេវាសុខភាព អនុវត្តគោលការណ៍ចត្តាឡីស័កតាមវិធានសុខាភិបាល ផ្តល់អាហារ ត្រៀមមធ្យោបាយដឹកជញ្ជូន ឱ្យបានដល់លំនៅដ្ឋាន និងបន្តតាមដានស្ថានភាពសុខភាព ជីវភាព និងផ្តល់សេវាតាមតម្រូវការផ្សេងៗ និងបន្តតាមដានស្ថានភាព នៅពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ ដែលពួកគាត់រស់នៅ។ លើសពីនេះទៅទៀត វិធានការអប់រំ បង្ការទប់ស្កាត់សកម្មភាពវិលត្រឡប់ទៅប្រទេសថៃវិញ

ក្នុងអំឡុងពេលដែលមានការរឹតបន្តឹង ពីប្រទេសគោលដៅក្នុងវិធានការទប់ស្កាត់វិបត្តិកូវីដ-១៩ និងដោះស្រាយវិបត្តិសេដ្ឋកិច្ច ការបង្កើនការស៊ើបអង្កេតរកមេខ្យល់ជួញដូរមនុស្ស ក្នុងដំណាក់កាលនេះ ការផ្តល់សេវាជួយជនរងគ្រោះ និងជនងាយរងគ្រោះ ត្រូវបានធ្វើឡើងកាន់តែសកម្ម។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួលពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ អន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

#### ១. ការកសាងច្បាប់

- **ក្រសួងយុត្តិធម៌** បានរៀបចំបន្តពិនិត្យសេចក្តីព្រាងច្បាប់ស្តីពី «អំពើពពោះជំនួស» និងច្បាប់ស្តីពី «ការប្រឆាំងអំពើរត់ពន្ធមនុស្ស»។
- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បាន និងកំពុងសិក្សារៀបចំសេចក្តីព្រាងច្បាប់ស្តីពី «ទេសន្តរប្រវេសន៍ការងារកម្ពុជានៅបរទេស»។

#### ២. សន្ធិសញ្ញា

- **ក្រសួងយុត្តិធម៌**
  - បាន និងកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាស្តីពី «ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ» ជាមួយសាធារណរដ្ឋឥណ្ឌា សាធារណរដ្ឋបេឡារុស និងសាធារណរដ្ឋតួកគី។
  - បាន និងកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាស្តីពី «បត្យាប័ន» ជាមួយសាធារណរដ្ឋឥណ្ឌា សាធារណរដ្ឋបេឡារុស និងសាធារណរដ្ឋតួកគី។
  - បាន និងកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាស្តីពី «ការផ្ទេរទណ្ឌិត» ជាមួយសាធារណរដ្ឋប៉េរូ សាធារណរដ្ឋកូរ៉េ សាធារណរដ្ឋតួកគី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ និងព្រះរាជាណាចក្រប៊ែលហ្ស៊ិក។

### ខ. ការបង្ការ ទប់ស្កាត់

#### ១. តាមរយៈការលើកកម្ពស់ការយល់ដឹង

##### ១.១. ការអប់រំដោយផ្ទាល់

##### ១.១.១. កិច្ចប្រជុំ និងវេទិកាផ្សព្វផ្សាយសាធារណៈ

នៅក្នុងខែកុម្ភៈ ឆ្នាំ២០២៣នេះ ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយស្តីពី ការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "**ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព**" ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ សាសនិកជន និងប្រជាពលរដ្ឋ សរុបចំនួន **១៤.៥៥៨**លើក មានអ្នកចូលរួមសរុបចំនួន **៦៦២.២២១**នាក់ ស្ត្រីចំនួន **៣៤៧.៥៩០**នាក់ (ធៀបនឹងខែមករា មានចំនួន **៦៥២.២៨០**នាក់ គឺមានការកើនឡើងចំនួន **៩.៩៤១**នាក់ ស្មើនឹង**១,៥២%**) ក្នុងនោះ ដូចមានតារាងលម្អិតខាងក្រោម៖

# តារាងទិន្នន័យកិច្ចប្រជុំ និងវេទិកាផ្សព្វផ្សាយសាធារណៈ

| ល.រ | ក្រសួង ស្ថាប័ន | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | រាជធានី-ខេត្ត | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| ក្រសួង ស្ថាប័ន | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ១៥១ | ៥.១១០ | ៣.២០១ | ១.១៥០ | ៥៨.១៣៦ | ៣១.០៤៦ |
| | សរុប ក្រសួង ស្ថាប័ន | ១៥១ លើក | ៥.១១០ នាក់ | ៣.២០១ នាក់ | ១.១៥០ លើក | ៥៨.១៣៦ នាក់ | ៣១.០៤៦ នាក់ |
| រាជធានី-ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | | | |
| ២ | ខេត្តកណ្តាល | ៨៩១ | ៤៨.៥៨៥ | ២៣.០៥៥ | ១.៤០៨ | ១០៩.៥៤៥ | ៥៥.០៦៩ |
| ៣ | ខេត្តបាត់ដំបង | ៨២៣ | ៤៧.៦៧១ | ២៥.៥៣០ | ៦១២ | ២២.២៨៩ | ១១.៤៨៧ |
| ៤ | ខេត្តពោធិ៍សាត់ | ៤៧០ | ៣២.៦២៦ | ១៦.៨៤៣ | ១៣៨ | ៤.៦២៨ | ២.៣៤៥ |
| ៥ | ខេត្តសៀមរាប | ២៩៥ | ១៨.៨២៤ | ១១.៨៣៥ | ១០៣ | ៣.២២៦ | ១.៩៧៥ |
| ៦ | ខេត្តកំពង់ឆ្នាំង | ៨៦៨ | ២១.១២៦ | ១១.៣៧៩ | ៤៥៥ | ៩.៩៣៩ | ៥.០៩៩ |
| ៧ | ខេត្តកំពង់ចាម | ២.៦២២ | ១១៤.៨៣១ | ៥៨.៥២៥ | ២ | ១០១ | ៧៣ |
| ៨ | ខេត្តព្រះសីហនុ | | | | | | |
| ៩ | ខេត្តព្រះវិហារ | ១០ | ២.៤៦០ | ១.៦៧៧ | | | |
| ១០ | ខេត្តស្វាយរៀង | | | | ១.០២៤ | ៥០.៥៦៥ | ២៧.៧៧៩ |
| ១១ | ខេត្តប៉ៃលិន | ៧៤ | ១.២៣៩ | ៣០៦ | ៣២ | ១.១៩០ | ២៥៣ |
| ១២ | ខេត្តកោះកុង | | | | ៧៧ | ១.៥៤៩ | ៦៧៥ |
| ១៣ | ខេត្តកំពត | | | | | | |
| ១៤ | ខេត្តកំពង់ធំ | ៤២៦ | ៥០.១១០ | ២៧.៤២៥ | ១៩ | ១.១៣៤ | ៥០៦ |
| ១៥ | ខេត្តតាកែវ | ៣៥៤ | ១២.៧៤៣ | ៦.៦៨១ | ១២១ | ៤.១៥៩ | ២.៣០២ |
| ១៦ | ខេត្តក្រចេះ | ១១ | ១.២៥៨ | ៤១០ | | | |
| ១៧ | ខេត្តកែប | ៣៣ | ៦.៦៦៥ | ៣.៨០៥ | ៥៤ | ២.៤៦៧ | ១.៤៦០ |
| ១៨ | ខេត្តកំពង់ស្ពឺ | | | | | | |
| ១៩ | ខេត្តស្ទឹងត្រែង | | | | | | |
| ២០ | ខេត្តរតនគិរី | | | | | | |
| ២១ | ខេត្តព្រៃវែង | | | | | | |
| ២២ | ខេត្តត្បូងឃ្មុំ | ៩ | ២.៣១៧ | ១.០៤៣ | ២.១៨៨ | ២៦.១១៧ | ១៤.៩២៧ |
| ២៣ | ខេត្តបន្ទាយមានជ័យ | | | | | | |
| ២៤ | ខេត្តឧត្តរមានជ័យ | | | | | | |
| ២៥ | ខេត្តមណ្ឌលគិរី | ១៣៨ | ១.៦១១ | ៨៧៩ | | | |
| | សរុប រាជធានី-ខេត្ត | ៧.០២៤លើក | ៣៦២.០៦៦នាក់ | ១៨៩.៣៩៣នាក់ | ៦.២៣៣លើក | ២៣៦.៩០៩នាក់ | ១២៣.៩៥០នាក់ |
| សរុបរួម ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត | | ចំនួន ១៤.៥៥៨ លើក | | ចំនួនមនុស្សសរុប ៦៦២.២២១ នាក់ | | ចំនួនស្ត្រី ៣៤៧.៥៩០ នាក់ | |

## ១.១.៣. ការផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សេងៗ

- ខេត្តសៀមរាប៖
  - **មន្ទីរទេសចរណ៍** បានចុះពង្រឹង និងទប់ស្កាត់ការជួញដូរមនុស្សមនុស្ស ក្នុងវិស័យទេសចរណ៍នៅតាមអាជីវកម្មស្នាក់នៅ ម៉ាស្សានិងស្ប៉ា ឌីស្កូតែក និងKTV បៀរហ្គាឌិន បានចំនួន **១៦**លើក មានអ្នកចូលរួមសរុប **១៤១**នាក់ ស្រី**១២៣**នាក់។

- **មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ** បានធ្វើការផ្សព្វផ្សាយអំពីការទប់ស្កាត់ និងរូបភាពនៃអំពើជួញដូរមនុស្ស ដល់សិស្សានុសិស្ស ដែលកំពុងសិក្សានៅសាលាវិចិត្រសិល្បៈភូមិភាគខេត្តសៀមរាប ព្រមទាំងបានបញ្ជ្រាបការផ្សព្វផ្សាយដល់សាធារណៈជន នៅក្នុងវិធីសម្តែងសិល្បៈ ទទួលប្រតិភូប្រធានាធិបតីអាឡឺម៉ង់ ចំនួន០៥លើក មានអ្នកចូលរួមសរុប **៣៧៤**នាក់ ស្រី **១៤៩**នាក់។

- **ខេត្តកំពង់ឆ្នាំង៖**
  - មន្ទីរអប់រំ យុវជន និងកីឡា បានបញ្ជ្រាបចំណេះដឹងពាក់ព័ន្ធនឹងការជួញដូរមនុស្ស តាមរយៈកិច្ចតាមប្រព័ន្ធអនឡាញ ដល់ប្រធានការិយាល័យអប់រំ រដ្ឋបាលក្រុង ស្រុកទាំង៨ និងសិស្សានុសិស្ស នៅក្នុងពេលគោរពទង់ជាតិមុនចូលរៀន និងនៅក្នុងមេរៀនសាលាផងដែរ។
  - ស្រុកទឹកផុសបានចុះផ្សព្វផ្សាយច្បាប់ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការជួញដូរមនុស្ស តាមរយៈកិច្ចប្រជុំគណៈបញ្ជាការឯកភាព កិច្ចប្រជុំ គ.ក.ស.ក និងកិច្ចប្រជុំសមាគមនារីដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ចំនួន ០៣លើក មានអ្នកចូលសរុបចំនួន **៦៥**នាក់ ស្រី **១៧**នាក់។
  - ស្រុកសាមគ្គីមានជ័យ បានផ្សព្វផ្សាយស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការជួញដូរមនុស្សកាធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ តាមរយៈកិច្ចប្រជុំ គ.ក.ស.ក ប្រចាំខែ មានអ្នកចូលរួម **២៥**នាក់ ស្រី **១២**នាក់ ។

- **ខេត្តបន្ទាយមានជ័យ៖**
  - **មន្ទីរអប់រំ យុវជន និងកីឡា** បាន៖ ១.ចុះផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់សាលាបឋមសិក្សា ចំនួន០៤ ក្នុងក្រុងប៉ោយប៉ែត និងនៅស្រុកថ្មពួក ដែលមានលោកគ្រូ អ្នកគ្រូ សិស្សានុសិសស្ស ចូលរួមសរុបចំនួន **៩៥៦**នាក់ ស្រី**៤៥០**នាក់។ **២.** បានបញ្ជ្រាបច្បាប់បង្ក្រាបអំពើជួញដូរមនុស្ស ដល់សិក្ខាកាមក្នុងវគ្គបណ្តុះបណ្តាលជំនាញឌីជីថល ចំនួន **៧៥**នាក់ ស្រី**១៧**នាក់។
  - **មណ្ឌលធនធានពលករទេសន្តរប្រវេសន៍** បានចុះផ្សព្វផ្សាយតាមសហគមន៍ស្តីពី សុវត្ថិភាពចំណាកស្រុក បានចំនួន ៦ស្រុក( ស្វាយចេក ថ្មពួក ព្រះនេត្រព្រះ មង្គលបូរី ម៉ាឡៃ ភ្នំស្រុក) ដែលមានអ្នកចូលរួមសរុប **៧១៤**នាក់ ស្រី**៥៦៥**នាក់( អតីតពលករ **២០៩**នាក់ ស្រី**១៥៦**នាក់)។

- **ខេត្តកំពង់ចាម៖**
  - **រដ្ឋបាលក្រុង ស្រុកទាំង១០** បានអប់រំផ្សព្វផ្សាយទៅតាមរយៈការប្រជុំគ.ស.ន.ក និងគ.ក.ន.ក ពាក់ព័ន្ធទៅនឹងការរំលោភសេពសន្ថវៈទៅលើស្ត្រីនិងកុមារ និងបញ្ហាចំណាកស្រុកទៅរកការងារធ្វើ ចៀសវាងការចាញ់បោកមេខ្យល់។
  - បានផ្សព្វផ្សាយដល់សហគមន៍ស្តីពី ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស តាមរយៈការចុះពិនិត្យតាមដានការប្រជុំក្រុមឪពុកម្តាយកុមារតូចអាយុ០-៣ឆ្នាំ តាមស្រុក ឃុំ ភូមិគោលដៅ។

- **ខេត្តឧត្តរមានជ័យ៖** ចុះបញ្ជ្រាបស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះការជួញដូរស្ត្រី-កុមារ បានចំនួន០៣ភូមិ ក្នុងក្រុងសំរោង គោលបំណងលើកកម្ពស់ការយល់ដឹងដល់សហមគមន៍អំពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការជួញដូរស្ត្រី កុមារ និងកិច្ចការពារជនរងគ្រោះ ដែលមានអ្នកចូលរួមសរុប **៥៧**នាក់ ស្រី**៤០**នាក់។

- **ខេត្តក្រចេះ៖** មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ បានរៀបចំកិច្ចប្រជុំប្រចាំខែ និងបានណែនាំផ្សព្វផ្សាយការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស វិធីទប់ស្កាត់និងការរំលោភបំពានផ្លូវភេទតាមគ្រប់រូបភាពដល់មន្ត្រីគ្រប់ជាន់ថ្នាក់ ចំនួន០១លើក។

១.១.៤. ការផ្សព្វផ្សាយរបស់អង្គការដៃគូ

- **ខេត្តសៀមរាប៖** អង្គការមូលនិធិអេ២១ ធ្វើការផ្សព្វផ្សាយដល់ស្ថាប័នពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិល បានចំនួន ០៥លើក មានអ្នកចូលរួមសរុប ៣២នាក់ ស្រី១៤នាក់។
- **ខេត្តបន្ទាយមានជ័យ៖** អង្គការកល្យាណមិត្ត បានចុះធ្វើកម្មវិធីអប់រំផ្សព្វផ្សាយស្តីពី ការចំណាកស្រុកដោយសុវត្ថិភាព និងចែកសម្ភារៈដល់ប្រជាពលរដ្ឋក្នុងសហគមន៍ចំនួន ៤៥០នាក់ ស្រី៣៤៨នាក់។

**១.២. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក**

- **ក្រុមជំនួយកិច្ចការបង្ក្រាប ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** បានផ្សព្វផ្សាយព័ត៌មាន និងច្បាប់ពាក់ព័ន្ធ ស្តីពីការងារបង្ក្រាបទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ តាមរយៈផេកហ្វេសប៊ុក មានអ្នកទស្សនាចំនួន **១.១១៥**នាក់។
- **ខេត្តសៀមរាប៖** មន្ទីរព័ត៌មាន បានផ្សព្វផ្សាយតាមវិទ្យុ **១៤០**លើក និងផ្សាយផ្ទាល់ **៤៥**លើក។
- **ខេត្តព្រៃវែង៖** មន្ទីរព័ត៌មាន បានផ្សព្វផ្សាយសារអប់រំតាមវិទ្យុ ចំនួន **៥០**លើក។

**១.៣. ការផ្សព្វផ្សាយតាមរយៈខួបករណ៍(IEC)**

- **ខេត្តសៀមរាប៖**
  - **រដ្ឋបាលស្រុកពួក** បានធ្វើការផ្សព្វផ្សាយ និងចែកខិតប័ណ្ណស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព បានចំនួន **៣.៦៦១**ខិត្តប័ណ្ណ។
  - **មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានចែកខិតប័ណ្ណ សម្រាប់ផ្តល់ព័ត៌មានអំពីលេខទូរស័ព្ទក្នុងការទំនាក់ទំនង ដែលអាចរាយការណ៍សុំកិច្ចអន្តរាគមន៍ ក្នុងករណីបានឃើញ ឬ បានជួបប្រទះអំពើហិង្សា អំពើជួញដូរមនុស្ស ឬ ការរំលោភបំពានលើស្ត្រី ពលករចំណាកស្រុក ដល់ប្រជាពលរដ្ឋ និងអាជ្ញាធរស្រុកក្រឡាញ់ ចំនួន **១៧២**សន្លឹក។
- **ខេត្តបន្ទាយមានជ័យ៖ អង្គការសាម៉ារីតាន់ភឺស** ផ្តល់ការអប់រំ និងចែកប័ណ្ណផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាពដល់មនុស្សចំនួន **៧.៨០២**នាក់(ស្រី**២៨៤**នាក់) កុមារ **១២៩**នាក់ (កុមារី**៦៤**នាក់)។

**១.៤. ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ**

- **ខេត្តបាត់ដំបង៖** តំណាងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចូលរួមធ្វើជាវាគ្មិននៅក្នុងកម្មវិធីសន្ទនាមតិនៅវិទ្យុជាតិចំការចេក ក្រោមប្រធានបទ "ទប់ស្កាត់ការចំណាកស្រុកស្វែងរកការងារដោយខុសច្បាប់" ០១លើក។
- **ខេត្តកំពង់ចាម៖** ក្រុមការងារជំនាញ គ.ខ.ប.ជ បានចូលរួមជាវាគ្មិនក្នុងកម្មវិធីវិទ្យុចំនួន **០៥**លើក។

## ២. ការបង្ក្រាប ទប់ស្កាត់តាមវិធានការជំនាញ

**២.១. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក**

- **ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត** បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុក ទៅក្រៅប្រទេសទាំងស្របច្បាប់ មិនស្របច្បាប់ និងដាច់ការទាក់ទងសរុបចំនួន **២២១.២២៤**នាក់ (ស្រី **១០២.០៥៦**នាក់) អនីតិជន **៣.៧៥៤**នាក់(ស្រី**១.៣២៨**នាក់) ក្នុងនោះមាន៖
  - ស្របច្បាប់ ចំនួន **១៦៣.៧៤២**នាក់ (ស្រី**៧៧.៤០៩**នាក់) អនីតិជន **៤០១**នាក់(ស្រី**១២០**នាក់)
  - មិនស្របច្បាប់ចំនួន **៥៧.១៣៣**នាក់ (ស្រី **២៤.៥១៦**នាក់) អនីតិជន **៣.១៧៩**នាក់ (ស្រី **១.១៥៥**នាក់)។
  - ដាច់ការទាក់ទងចំនួន **៣៤៩**នាក់ (ស្រី **១៣១**នាក់) អនីតិជន **១៥៦**នាក់(ស្រី**៥៣**)។

- **ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត** បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកត្រឡប់មកវិញដោយខ្លួនឯងពីក្រៅប្រទេសទាំងស្របច្បាប់ និងមិនស្របច្បាប់ សរុបចំនួន **១២៧.២៩៣**នាក់ (ស្រី**៥៨.៤៣២**នាក់) អនីតិជន **៤៤២**នាក់ (ស្រី **១៦៦**នាក់)។
- **កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ** បានធ្វើការទប់ស្កាត់ពលរដ្ឋខ្មែរ ដែលធ្វើចំណាកស្រុកទៅប្រទេសថៃដោយខុសច្បាប់ ចំនួន **០១**លើក មនុស្សចំនួន **៧២**នាក់(ស្រី **៣៦**នាក់) បានធ្វើកិច្ចសន្យាអប់រំ ណែនាំរួចឱ្យត្រឡប់ទៅលំនៅដ្ឋានវិញ។

**២.២. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ**

▪ **អគ្គស្នងការដ្ឋាននគរបាលជាតិ**

- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ តាកែវ កំពង់ធំ កែប និងខេត្តបន្ទាយមានជ័យ បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ចារកម្ម ដល់ម្ចាស់អាជីវកម្ម ផ្ទះសំណាក់ ហាងម៉ាស្សា បានចំនួន **១១៨**គោលដៅ មនុស្សចំនួន **៦៨៨**នាក់(ស្រី **៣៦៨**នាក់)។
- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង ក្រចេះ បាត់ដំបង ព្រះវិហារ តាកែវ កោះកុង និងខេត្តបន្ទាយមានជ័យ បានល្បាតឃ្លាំមើលគោលដៅសង្ស័យប្រព្រឹត្តបទល្មើស ចំនួន **២០**លើក។

**២.៣. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស**

▪ **ក្រសួងមហាផ្ទៃ**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (**ក្រុមការងារអនុវត្តច្បាប់**) បានធ្វើសម្ភាសន៍ពលរដ្ឋខ្មែរ និងជនបរទេស ដែលបានដាក់ពាក្យសុំចុះបញ្ជីការរៀបអាពាហ៍ពិពាហ៍ បានចំនួន **២០៨**នាក់(ស្រី**២២**នាក់) មាន **១៥**សញ្ជាតិ ហើយបានវាយតំលៃបញ្ជូនឱ្យក្រុមការងារច្រកចេញចូលតែមួយបានចំនួន **១៤២**នាក់(ស្រី**១០**នាក់)។ បានប្រមូលព័ត៌មានពីសុខទុក្ខនារីខ្មែរ ដែលរៀបការទៅរស់នៅប្រទេសកូរ៉េខាងត្បូងតាមរយៈទូរស័ព្ទ ចំនួន ០៩នាក់(ស្រី០៨នាក់) មានសេចក្តីសុខធម្មតា។

**៣. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ**

- **ខេត្តសៀមរាប**
  - **មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានចុះផ្សព្វផ្សាយតាមដានត្រួតពិនិត្យ និងទប់ស្កាត់ពលកម្មកុមារងាយរងគ្រោះ តាមស្រុកគោលដៅ ក្នុងវិស័យឧស្សាហកម្ម (ចំការដំឡូងមី និងសិប្បកម្មផលិតឥដ្ឋ) បានចំនួន ០៣លើក និង
  - **រដ្ឋបាលស្រុកអង្គរជុំ** បានសហការជាមួយអង្គការជំហ៊ានដំបូង ធ្វើការផ្សព្វផ្សាយដល់ក្លិបកុមារចំនួន០២ឃុំ ស្តីពី ផលប៉ះពាល់នៃការរៀបការវ័យក្មេង និងគ្មានអំពើហិង្សាក្នុងទំនាក់ទំនង បានចំនួន ០២លើក ដែលមានអ្នកចូលរួមសរុប **២៤៧**នាក់ ស្រី**១៦២**នាក់។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### ១. ការងារអនុវត្តច្បាប់

**១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ**

អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន **១៦**ករណី/**១៣**ករណី (ធៀបនឹងខែមករា កើន០៣ករណី ស្មើនឹង **២៣,០៧%**) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន **២០**នាក់ (ស្រី០៣នាក់) ជនសង្ស័យជាអនីតិជន០៦នាក់។

សង្គ្រោះជនរងគ្រោះ ចំនួន **២៣**នាក់(ស្រី**២២**នាក់) មានៈ អាយុក្រោម១៥ឆ្នាំ **១៣**នាក់ អាយុ១៥-១៧ឆ្នាំ ០៤នាក់ និងអាយុ១៨ឆ្នាំឡើង ០៦នាក់ (ប្រគល់ឱ្យសង្គមកិច្ច ០៨នាក់ និងប្រគល់ឱ្យគ្រួសារ **១៥**នាក់) ក្នុងនោះចែកជាៈ

❖ ករណីអំពើជួញដូរមនុស្ស

បង្ក្រាបបាន ០២ករណី/០ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ០៣នាក់(ស្រី០១នាក់) ជនសង្ស័យជាអនីតជន ០១នាក់។ សង្គ្រោះជនរងគ្រោះចំនួន ០២នាក់(ស្រី០២នាក់) មានៈ អាយុក្រោម១៥ឆ្នាំ ០១នាក់ អាយុ១៥-១៧ឆ្នាំ ០១នាក់ (ប្រគល់ឱ្យគ្រួសារ ០២នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ (ស្រី) | ជនសង្ស័យ |
|---|---|---|---|
| -ការនាំចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ០២ | ០២ (០២) | ០៣ (អនី.០១) |
| *សរុប* | *០២ ករណី* | *០២ (០២) នាក់* | *០៣ នាក់ (អនី.០១)* |

❖ ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន ១៤ករណី/១៣ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ១៧នាក់(ស្រី០២នាក់) ជនសង្ស័យជាអនីតិជន ០៥នាក់។ សង្គ្រោះជនរងគ្រោះចំនួន ២១នាក់(ស្រី២២នាក់) មានៈ អាយុក្រោម១៥ឆ្នាំ ១២នាក់ អាយុ១៥-១៧ឆ្នាំ០៣នាក់ និងអាយុ១៨ឆ្នាំឡើង០៦នាក់ (ប្រគល់ឱ្យសង្គមកិច្ច០៨នាក់ ប្រគល់ឱ្យគ្រួសារ១៣នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ (ស្រី) | ជនសង្ស័យ |
|---|---|---|---|
| -ស្ថានទម្ងន់ទោសនៃសញ្ចារកម្ម | ០២ | ០៨ (០៨) | ០២ |
| -រូបភាពនិងសម្ភារៈអាសអាភាសនៃកុមារ | ០១ | ០១ (០១) | ០១ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៩ | ០៩ (០៩) | ១២ (អនី.០៥) |
| -អំពើអាសប្រផាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០២ | ០៣ (០៣) | ០២ |
| *សរុប* | *១៤ ករណី* | *២១ (២១) នាក់* | *១៧ នាក់ (អនី.០៥)* |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និង ផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

#### ១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានា និងទទួលបានពីសមត្ថកិច្ចក្នុងស្រុក សរុបចំនួន២២នាក់ (ស្ត្រី១១នាក់)សកម្មភាពមានដូចជាៈ
  - ជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវបានធ្វើមាតុភូមិនិវត្តពីក្រៅប្រទេស ចំនួន១១នាក់(ស្ត្រី) មកពីប្រទេសចិន ១១នាក់ បានសម្ភាសន៍ចំនួន ០៥នាក់(ករណីអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ/បង្ខំ ០៣នាក់ និងងាយរងគ្រោះ ០២នាក់) មិនបានសម្ភាសន៍ ០៥នាក់ និងមិនសហការ ០១នាក់។
  - បានទទួលពីនគរបាលមានសមត្ថកិច្ចនៅក្នុងស្រុកចំនួន ១១នាក់ (បុរស) ជាករណីងាយរងគ្រោះដោយអំពើជួញដូរមនុស្ស។

- អគ្គស្នងការដ្ឋាននគរបាលជាតិ
  - **នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន** បានសម្ភាសន៍ជនរងគ្រោះ ដែលបានវិលត្រឡប់មកពីក្រៅប្រទេស ចំនួន **២៧**នាក់(ស្រី) មកពីប្រទេសចិន ២៦នាក់ និងប្រទេសម៉ាឡេស៊ី ០១នាក់ ក្នុងនោះករណីរងគ្រោះដោយអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ ១៨នាក់ ស្នាក់នៅខុសច្បាប់ ០៨នាក់ និងកេងប្រវ័ញ្ចប្រាក់ឈ្នួល ០១នាក់។
  - **ខេត្តកោះកុង៖** បានទទួល និងសម្ភាសពលករខ្មែរ ដែលអាជ្ញាធរបរទេសថៃបញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន **០៧**លើក មនុស្សចំនួន **១៩**នាក់(ស្រី**០៦**នាក់)។
  - **ខេត្តបន្ទាយមានជ័យ៖** បានទទួលពលរដ្ឋខ្មែរ ដែលអាជ្ញាធរថៃបញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន **៣០០**នាក់(ស្រី**៧៨**នាក់ កុមារ **៤៧**នាក់ កុមារី **៣៦**នាក់)។
  - **ខេត្តស្វាយរៀង៖** បានទទួលពលរដ្ឋខ្មែរ ដែលអាជ្ញាធរវៀតណាមបញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន **០៣**លើក មនុស្សចំនួន **៦៩**នាក់(ស្រី**៣៩**នាក់) អនីតិជន **៥៦**នាក់(ស្រី**១៧**នាក់)។

**២. ការផ្ដល់សេវា និងការស្ដារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស**

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្សទៅមណ្ឌលស្ដារនីតិសម្បទា សរុបចំនួន **០៩**នាក់ (ស្ត្រី **០៦**នាក់ កុមារី **០៣**នាក់)។

**៣. ការធ្វើសមាហរណកម្មជនរងគ្រោះ និងជនងាយរងគ្រោះ**

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានធ្វើសមាហរណកម្មជនរងគ្រោះ និងសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្ស អំពើអាជីវកម្មផ្លូវភេទ ត្រឡប់ទៅសហគមន៍វិញចំនួន **០៩**នាក់ (ស្ត្រី **០៩**នាក់) ជាករណីអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ/បង្ខំ ០៤នាក់ ជួញដូរពលកកម្ម ០២នាក់ និងងាយរងគ្រោះ ០៣នាក់។

# III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

## ក. ការបណ្ដុះបណ្ដាល និងសិក្ខាសាលា

### ១. ការងារបណ្ដុះបណ្ដាល

- **ខេត្តស្វាយរៀង៖** មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ សហការជាមួយក្រុមហ៊ុនចំនួន៣ បើកវគ្គបណ្ដុះបណ្ដាល ស្ដីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ច្បាប់ស្ដីពីការងារ សុខភាព និងសុវត្ថិភាព ការងារ និងការជួយសង្គ្រោះបឋម ចំនួន០៦វគ្គ ដែលមានសិក្ខាកាមចូលរួមសរុបចំនួន **១០៥**នាក់ ស្រី **៧៧**នាក់។
- **ខេត្តត្បូងឃ្មុំ៖** ស្នងការដ្ឋាននគរបាល សហការជាមួយអង្គការ IJM ធ្វើការបើកវគ្គបណ្ដុះបណ្ដាល ស្ដីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដល់សិក្ខាកាមចំនួន **៥០**នាក់ ស្រី**០៧**នាក់។

### ២. សិក្ខាសាលា

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** សហការជាមួយអង្គការរតនៈអ៊ីនធើណេសិនណល និង ASEAN-ACT រៀបចំសិក្ខាលាផ្សព្វផ្សាយសារាចរណ៍ណែនាំលេខ ០១១ ស្ដីពីការងារសមាហរណកម្ម និងតាមដានជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងរំលោភបំពានផ្លូវភេទដែលស្នាក់នៅមណ្ឌលរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ ក្រោមអធិបតីភាពឯកឧត្ដម **នឹម ថូត** រដ្ឋលេខាធិការក្រសួង ស.អ.យ នៅខេត្តព្រះសីហនុ។
- **ខេត្តសៀមរាប៖** មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានរៀបចំសិក្ខាសាលាបណ្ដុះបណ្ដាលស្ដីពី បទបញ្ញត្តិពាក់ព័ន្ធនឹងទេសន្តរប្រវេសន៍ដើម្បីស្វែងរកការងារប្រកបដោយសុវត្ថិភាព ការជ្រើសរើសពលករដោយក្រមសីលធម៌ និងសេវាកម្មដែលឆ្លើយតបទៅនឹងបញ្ហាយេនឌ័រ មានការគាំទ្រពីអង្គការ ILO បានចំនួន **០៥**លើក ដែលមានអ្នកចូលរួមសរុប **១៧២**នាក់ ស្រី ៨៤នាក់។

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ១. សន្និសីទ

លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ រួមនិង លោកជំទាវ **វ៉ែនសិរីលក្ខិណា** អគ្គលេខាធិការរង គ.ជ.ប.ជ បានចូលរួមសន្និសីទថ្នាក់រដ្ឋមន្ត្រីកិច្ចប្រជុំ Bali Process លើកទី៨ នៅប្រទេសអូស្ត្រាលី។

### ២. ក្នុងប្រជុំក្នុងប្រទេស

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖**

  លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បាន អញ្ជើញដឹកនាំ៖ **១**.កិច្ចប្រជុំរៀបចំសេចក្តីព្រាងអនុស្សារណៈយោគយល់ (MOU) រវាងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃសាធារណៈរដ្ឋកូរ៉េ ពាក់ព័ន្ធនឹងកិច្ចសហការក្នុងការប្រយុទ្ធ ប្រឆាំងអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែន។ ទីស្តីការក្រសួងមហាផ្ទៃ។ **២**.កិច្ចប្រជុំពិភាក្សាកែសម្រួល អនុស្សរណៈ នៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋ ឥណ្ឌា ស្តីពីកិច្ចសហប្រតិបត្តិការសម្រាប់ការងារទប់ស្កាត់អំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ការ សង្គ្រោះ ការស្តារឡើងវិញ ការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរ មនុស្ស។ **៣**. កិច្ចប្រជុំដើម្បីពិនិត្យ និងពិភាក្សារបាយការណ៍ សិក្សារៀបចំដោយវិទ្យាស្ថានអភិវឌ្ឍន៍បរទេស (ODI) តាមប្រព័ន្ធអនឡាញ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។

- **ខេត្តបន្ទាយមានជ័យ៖** លោកស្រីប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ សហការជាមួយអង្គការ IOM ដឹកនាំអង្គប្រជុំប្រឹក្សាយោបល់ អនុវត្តគម្រោងក្រោមប្រធានបទ «ពង្រឹងសុវត្ថិភាពសុខភាពតាមរយៈ ការធ្វើផែនទីប្រជាជនចល័តក្នុងតំបន់ និងអនុតំបន់មេគង្គ និងបំលាស់ទីរបស់ពលករនៅតាមច្រក» មានអ្នកចូលរួម **៣៥**នាក់ ស្រី**១១**នាក់។

### ៣. ការងារជំនួបពិភាក្សា

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖**
  - លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បាន ទទួលជួបពិភាក្សាការងារ នៅសាលប្រជុំគ.ជ.ប.ជ ជាមួយ៖ **១**.លោក Alex Duke នាយកអង្គការ ASEAN-ACT ប្រចាំតំបន់ និងសហការី ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា និង រចនាសម្ព័ន្ធ ក៏ដូចជាសកម្មភាពការងារ របស់ គ.ជ.ប.ជ និងកិច្ចសហប្រតិបត្តិការនានា ជាមួយបណ្តាអង្គ ការជាតិ អន្តរជាតិ និងបណ្តាប្រទេសជាមិត្តទាំងនៅក្នុងតំបន់ និងពិភពលោក។ **២**.លោកឧត្តម សេនីយ៍ទោ Siriwish Chantechasitkul ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស នៃស្ថាប័ន ស៊ើបអង្កេតពិសេស (DSI) នៃរដ្ឋាភិបាលប្រទេសថៃ រួមនិងសាហការី ពាក់ព័ន្ធនឹងស្ថានភាព នៃអំពើ ជួញដូរមនុស្ស និងកិច្ចសហប្រតិបត្តិការ រវាងសមត្ថកិច្ចនៃប្រទេសទាំងពីរកម្ពុជា-ថៃ។

- **ខេត្តសៀមរាប៖** លោកស្រី **យូ សុភា** អនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ និងក្រុមការងារ បានទទួលជួប ពិភាក្សាការងារ៖ **១**.ជាមួយអង្គការយូនីសេហ្វប្រចាំកម្ពុជា ស្តីពីកិច្ចការពារកុមារ។ **២**.ជាមួយអង្គការ អន្តរជាតិខាងការងារ(ILO) ស្តីពី ការអនុវត្តកម្មវិធីនានារបស់ស្ថាប័ន និងអង្គការដៃគូពាក់ព័ន្ធ លើការ ផ្តល់ភាពអង់អាចទៅដល់ពលករទេសន្តរប្រវេសន៍។

## គ. ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំង ប្រទេសគឺ **៥៩**លើក មានអ្នកចូលរួមសរុប **៣.២០០**នាក់(ស្រី **៩៦៨**នាក់) ក្នុងនោះមាន គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស **២០**លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា **០១**លើក និង លេខាធិការដ្ឋានរាជធានី ខេត្ត **៣៨**លើក។**(ឧបសម្ព័ន្ធ១)**

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ **០៤ចំណុច** និងវិធានការ **០៦ចំណុច** របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់ កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួងស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

### ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឱ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

### គ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។

- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឱ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅខែមីនា ឆ្នាំ ២០២៣

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឱ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឱ្យបានត្រឹមត្រូវ។

៩. បន្តរៀបចំវិធានការ "**គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី**" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១០. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១១. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

១២. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ.........ខែ.........ឆ្នាំ ខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី.........ខែ.........ឆ្នាំ២០២៣
**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ជូ_ប៊ុនអេង

**ចម្លងជូន**
- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

"**ដើម្បីគោរពជូនជាសេចក្តីរាយការណ៍**"

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន
-សមាជិកក្រុមការងារគ.ជ.ប.ជ
-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**-ដើម្បីជូនជ្រាប-**

-ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ៥៩លើក) មនុស្សចំនួន ៣.២០០នាក់ (ស្រី ៩៦៨នាក់)

| ស្ថាប័ន សម្របសម្រួល | សកម្មភាព |
|---|---|
| **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)** | ▪ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួមជាអធិបតី៖<br>- កិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២២ និងលើកទិសបន្ត ឆ្នាំ២០២៣ របស់គ.ខ.ប.ជ ខេត្តសៀមរាប ដែលមានអ្នកចូលរួមសរុប ២២៥នាក់ ស្រី ៩៥នាក់។<br>- បិទសិក្ខាសាលាស្តីពីការរៀបចំសៀវភៅផែនការសកម្មភាពប្រចាំឆ្នាំ ស្តីពីសុខភាពជនទេសន្តរប្រវេសន៍ (២០២៣-២០២៥) ដែលរៀបចំដោយក្រសួងសុខាភិបាល និងអង្គការ IOM នៅខេត្តសៀមរាប។<br>- សន្និបាតត្រួតពិនិត្យលទ្ធផលការងារឆ្នាំ២០២២ និងលើកទិសដៅការងារឆ្នាំ២០២៣ របស់ក្រសួងមហាផ្ទៃ និងប្រកាសផ្តល់ជ័យលាភី ប័ណ្ណសរសើរ លិខិតសរសើរដល់រដ្ឋបាលឃុំ សង្កាត់ ប៉ុស្តិ៍នគរបាលរដ្ឋបាល នៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ក្រោមអធិបតីភាពដ៏**ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**។<br>▪ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញ៖<br>- កិច្ចប្រជុំរៀបចំសេចក្តីព្រាងអនុស្សរណៈយោគយល់(MOU) រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ ពាក់ព័ន្ធនឹងកិច្ចសហការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែន ក្រោមការដឹកនាំរបស់ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- យុទ្ធនាការគាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ិនធឺណិត ក្រោមប្រធានបទ «តោះ!នាំគ្នានិយាយអំពីការប្រើប្រាស់អ៊ីនធឺណិតប្រកបដោយសុវត្ថិភាពសម្រាប់កុមារ» ក្រោយអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅវិទ្យាស្ថានបច្ចេកវិទ្យា(តិចណូ) មានអ្នកចូលរួម ១.១០០នាក់។<br>- កិច្ចប្រជុំពិភាក្សាកែសម្រួលអនុស្សរណៈ នៃការយោគយល់រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋឥណ្ឌា ស្តីពីកិច្ចសហប្រតិបត្តិការសម្រាប់ការងារទប់ស្កាត់អំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ការសង្គ្រោះ ការស្តារឡើងវិញ ការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំគ.ជ.ប.ជ មានអ្នកចូលរួម ១១នាក់ ស្រី ០៣នាក់។<br>- កិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២២ និងលើកទិសបន្ត ឆ្នាំ២០២៣ របស់គ.ខ.ប.ជ ខេត្តសៀមរាប។ |

- បិទសិក្ខាសាលាស្តីពីការរៀបចំសៀវភៅផែនការសកម្មភាពប្រចាំឆ្នាំ ស្តីពីសុខភាពជនទេសន្តរប្រវេសន៍ (២០២៣-២០២៥) ដែលរៀបចំដោយក្រសួងសុខាភិបាល និងអង្គការ IOM នៅខេត្តសៀមរាប។
- ចូលរួមជំនួបពិភាក្សាការងារជាមួយលោកឧត្តមសេនីយ៍ទោ Siriwish Chantechasitkul ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស នៃស្ថាប័នស៊ើបអង្កេតពិសេស (DSI) នៃរដ្ឋាភិបាលប្រទេសថៃ និងសហការី ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំ គ.ជ.ប.ជ។

▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**

- លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ០៩ច្បាប់ លិខិតចូល ១០ច្បាប់។
- លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ០៤ច្បាប់ លិខិតចូល ២៣ច្បាប់។
- ព័ត៌មានស្រាវជ្រាវ ពីគេហទំព័រព័ត៌មាននានា រក្សាទុកក្នុងបណ្ណាល័យ wiki ncct convert ជាPDF បានចំនួន ៧០ច្បាប់។
- អាប់ឡូតរូបភាពសកម្មភាព គ.ជ.ប.ជ និង គ.ខ.ប.ជ ចូលបណ្ណាល័យរូបភាពក្នុងប្រព័ន្ធ Wiki បានចំនួន ២៥សកម្មភាព។
- អាប់ឡូតឯកសារចូលបណ្ណាល័យវីគីបានចំនួន ០៨សច្បាប់។

▪ **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់**

- លោកប្រធានក្រុមជំនួយកិច្ចការ បានអញ្ជើញចូលរួម ពិនិត្យពិភាក្សាផ្តល់ធាតុចូលដើម្បីត្រៀមឆ្លើយតប តាមវិស័យរៀងខ្លួននូវសំណួរទាំង១៧ចំណុច របស់ស្ថានទូតអាមេរិក ចំនួន ០២លើក។
- លោកឧត្តមសេនីយ៍ទោ អនុប្រធានក្រុមជំនួយកិច្ច បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ស្តីពី ការសម្អាតប្រាក់នៅក្នុងប្រទេសកម្ពុជា ក្រោមអធិបតីភាព លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ នៅសាលប្រជុំ គ.ជ.ប.ជ។

▪ **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**

- ឯកឧត្តម ឧត្តមសេនីយ៍ឯក **លី តុងហ៊ុយ** អគ្គលេខាធិការរង បាន៖ ១.ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់លើឯកសារបណ្តុះបណ្តាលស្តីពី កិច្ចការពារកុមារពីការកេងប្រវ័ញ្ច និងរំលោភបំពានតាមប្រព័ន្ធអនឡាញ នៅខេត្តកែប ដែលមានអ្នកចូលរួម ១៩នាក់ ស្រី១១នាក់។ ២.ចូលរួមសិក្ខាសាលាទ្វេភាគីស្តីពី កិច្ចសហប្រតិបត្តិការទ្វេភាគី កម្ពុជា-ថៃ ពិសេសលើពលករទេសន្តរប្រវេសន៍ រវាងខេត្តបន្ទាយមានជ័យ និងខេត្តស្រះកែវ។
- លោកអនុប្រធានក្រុម អមដំណើរ លោកជំទាវអគ្គលេខាធិការ ចូលរួមកិច្ចប្រជុំប្រចាំឆ្នាំ២០២២ ក្រុមការងារការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស ស្តីពី ការវាយតម្លៃលទ្ធផលការងារ បញ្ហាប្រឈម ក្រោមអធិបតីភាពឯកឧត្តម **ញ៉ឹក វណ្ណារ៉ា** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅទីស្តីការក្រសួងមហាផ្ទៃ មានអ្នកចូលរួម ៤៥នាក់ ស្រី១៤នាក់។

| | |
|---|---|
| | ▪ **ក្រុមជំនួយកិច្ចការយុត្តិធម៌**<br>- ឯកឧត្តម ឧត្តមសេនីយ៍ទោ **នី គឹមស្រេន** អគ្គលេខាធិការរង បានចូលរួមកិច្ចប្រជុំឆ្លើយតបបញ្ហាសិទ្ធិមនុស្ស ក្រោមអធិបតីភាពលោកជំទាវ អគ្គលេខាធិការ ០១លើក។<br>▪ **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ**<br>- លោកជំទាវ ឧត្តមសេនីយ៍ទោ **វ៉ន សិរីលក្ខិណា** អគ្គលេខាធិការរង បានអញ្ជើញចូលរួម៖ **១.**កិច្ចប្រជុំពិភាក្សាលើការងារកិច្ចសហប្រតិបត្តិការរវាងប្រទេសថៃ និងកម្ពុជា ស្តីពីកិច្ចការពារកុមារអន្តរប្រទេស រៀបចំឡើងដោយ អគ្គនាយកដ្ឋានសេវាសង្គមកិច្ច នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ **២.**ជួបសំណេះសំណាលជាមួយ លោក **Alex Duke** នាយកអង្គការ ASEAN-ACT ប្រចាំតំបន់ និងសហការី ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃនិងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា និងរចនាសម្ព័ន្ធ ក៏ដូចជាសកម្មភាពការងារ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងកិច្ចសហប្រតិបត្តិការនានាជាមួយបណ្តាអង្គការជាតិ អន្តរជាតិ និងបណ្តាប្រទេសជាមិត្តទាំងអស់នៅក្នុងតំបន់ និងពិភពលោក នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ **៣.**ជាគ្រូឧទ្ទេសក៍ក្នុងវគ្គបណ្តុះបណ្តាលស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះ នៅសាលាស្រុក កំរៀងខេត្តបាត់ដំបង មានអ្នកចូលរួម ៣៥នាក់ ស្រី ២៣នាក់។ **៤.**ជំនួបពិភាក្សាការងារជាមួយលោកឧត្តមសេនីយ៍ទោ **Siriwish Chan techasitkul** ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស នៃស្ថាប័នស៊ើបអង្កេតពិសេស (DSI) នៃរដ្ឋាភិបាលប្រទេសថៃ និងសហការី ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំ គ.ជ.ប.ជ។ **៥.**កិច្ចប្រជុំដើម្បីពិនិត្យ និងពិភាក្សារបាយការណ៍សិក្សារៀបចំដោយវិទ្យាស្ថានអភិវឌ្ឍន៍បរទេស(ODI) តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។<br>- លោកឧត្តមសេនីយ៍ត្រី អនុប្រធានក្រុមជំនួយកិច្ចការស្តីទី លោកវរសេនីយ៍ត្រី នាយរងការិយាល័យស្រាវជ្រាវព័ត៌មាន ត្រួតពិនិត្យ បានអញ្ជើញចូលរួម កិច្ចប្រជុំពិភាក្សាពិគ្រោះយោបល់ ស្តីពីបញ្ហាការសម្អាតប្រាក់នៅក្នុងប្រទេសកម្ពុជា ក្រោមអធិបតីភាពលោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ។<br>▪ **ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍**<br>- ឯកឧត្តម ឧត្តមសេនីយ៍ឯក **ខៀវ ចាន់រ៉ា** អគ្គលេខាធិការរង និងលោកវរសេនីយ៍ទោ អនុប្រធានក្រុម បានចូលរួមសិក្ខាសាលាទ្វេភាគីស្តីពី កិច្ចសហប្រតិបត្តិការទ្វេភាគី កម្ពុជា-ថៃ ពិសេសលើពលករទេសន្តរប្រវេសន៍ រវាងខេត្តបន្ទាយមានជ័យ និងខេត្តស្រះកែវ។<br>- លោកវរសេនីយ៍ទោ អនុប្រធានក្រុមជំនួយកិច្ចការ បានចូលរួម៖ **១.**ប្រជុំឆ្លើយតបទៅនឹងសំណួររបស់គណៈកម្មាធិការសិទ្ធិមនុស្ស ក្រសួងមហាផ្ទៃក្រោមការអធិបតីភាពលោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ នៅសាលប្រជុំគ.ជ.ប.ជ។ **២.**ពិធីផ្សព្វផ្សាយសារាចរណ៍ណែនាំលេខ ០១១ ស្តីពីការងារសមាហរណកម្ម និងតាមដានជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងរំលោភបំពានផ្លូវភេទ ដែលស្នាក់នៅក្នុងមណ្ឌលរដ្ឋ អង្គការដៃគូ និងសហគមន៍ ក្រោមការរៀបចំដោយក្រសួង ស.អ.យ សហការជាមួយអង្គការ Ratanak International, Australian Aid និង Tredick លេខាទី១ ស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា នៅខេត្តព្រះសីហនុ។ **៣.** សិក្ខាសាលារៀបចំផែនការសកម្មភាពប្រចាំឆ្នាំ ស្តីពីសុខភាពជនទេសន្តរប្រវេសន៍ ២០២៣-២០២៥ ដែលរៀបចំដោយក្រសួងសុខាភិបាល សហការជាមួយអង្គការ IOM នៅខេត្តសៀមរាប។ |

| | |
|---|---|
| **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា** | - បានចូលរួមជាគ្រូឧទ្ទេសក៍វគ្គបណ្តុះបណ្តាលស្តីពី ដំណើរការនៃការគ្រប់គ្រងករណីជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងជំនាញប្រឹក្សាយោបល់មូលដ្ឋាន នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ៣៨លើក អ្នកចូលរួមសរុបចំនួន ១.៧៦៥នាក់(ស្រី ៨២២នាក់)** | |
| **ខេត្តកណ្តាល** | - លេខាធិការដ្ឋាន គ.ខ.ប.ជ ប្រជុំបូកសរុបរបាយការណ៍ប្រចាំខែ ០១លើក មានអ្នកចូលរួម **២៧**នាក់ ស្រី**២០**នាក់។<br>- បានប្រជុំផ្សព្វផ្សាយស្តីពី ការដាក់ឲ្យអនុវត្តន៍ផែនការកិច្ចការពារកុមារខេត្ត រយៈពេល៣ឆ្នាំ (២០២៣-២០២៥) នៅសាលប្រជុំសាលាខេត្ត មានអ្នកចូលរួមចំនួន **៨៣**នាក់ ស្រី**៥៩**នាក់។<br>- ក្រុមការងារក្រុង-ស្រុក ប្រជុំប្រចាំខែ ចំនួន ០៧លើក អ្នកចូលរួម **១៦២**នាក់ ស្រី**១០២**នាក់។<br>- បានចូលរួមកម្មវិធីយុទ្ធនាការគាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធឺណិត ក្រោមប្រធានបទ «រួមគ្នាលើកកម្ពស់ការសន្ទនា និងការអប់រំសុវត្ថិភាពកុមារ និងយុវជនក្នុងយុគសម័យឌីជីថល នៅវិទ្យាស្ថានបច្ចេកទេសកម្ពុជា(តិចណូ) ០១លើក។ |
| **ខេត្តកំពង់ចាម** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំប្រជុំប្រចាំខែកុម្ភៈ ០១លើក។<br>- បានសហការជាមួយអង្គការភ្នំស្រីដើម្បីអភិវឌ្ឍន៍ ចូលរួមជាគ្រូឧទ្ទេសស្តីពីយន្តការដោះស្រាយពាក្យ បណ្តឹងរបស់ពលករ នៅឃុំពាមជីកង ស្រុកកងមាស ចំនួន ០១លើក មានអ្នកចូលរួម **២០**នាក់ ស្រី **០១**នាក់។<br>- បានរៀបចំកិច្ចប្រជុំកសាងផែនការសកម្មភាពឆ្នាំ២០២៣ របស់ក្រុមការងារទាំង៦ ដើម្បីលើកផែនការកំណត់បញ្ហាប្រឈម និងលើកទិសដៅបន្តក្នុងការជួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សឱ្យកាន់តែមានប្រសិទ្ធិភាព នៅសាលប្រជុំសាលាខេត្ត។ |
| **ខេត្តកោះកុង** | - បានចូលរួមកម្មវិធីយុទ្ធនាការគាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធឺណិត ក្រោមប្រធានបទ «រួមគ្នាលើកកម្ពស់ការសន្ទនា និងការអប់រំសុវត្ថិភាពកុមារ និងយុវជនក្នុងយុគសម័យឌីជីថល នៅវិទ្យាស្ថានបច្ចេកទេសកម្ពុជា(តិចណូ) ០១លើក។ |
| **ខេត្តរតនគិរី** | - ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានដឹកនាំកិច្ចប្រជុំដើម្បីពិនិត្យ និងពិភាក្សារៀបចំក្រុមការងារចុះសំណេះសំណាលជាមួយស្ត្រីបំរើអាជីវកម្មក្រៅប្រព័ន្ធសេវាកម្សាន្តនានា នៅក្នុងក្រុងបានលុង ០១លើក និងបានចូលរួមកម្មវិធីយុទ្ធនាការគាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធឺណិត ក្រោមប្រធានបទ «រួមគ្នាលើកកម្ពស់ការសន្ទនា និងការអប់រំសុវត្ថិភាពកុមារ និងយុវជនក្នុងយុគសម័យឌីជីថល នៅវិទ្យាស្ថានបច្ចេកទេសកម្ពុជា(តិចណូ) ០១លើក។ |
| **ខេត្តព្រៃវែង** | - ឯកឧត្តម **ជា សុមេធី** អភិបាលខេត្ត និងប្រធាន គ.ខ.ប.ជ បានដឹកនាំកិច្ចប្រជុំគណៈបញ្ជាការឯកភាព ដើម្បីពង្រឹងការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការផ្សព្វផ្សាយការងារភូមិ ឃុំមានសុវត្ថិភាព និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទគ្រប់ទម្រង់ មានអ្នកចូលរួម **៩៩**នាក់។<br>- ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមកម្មវិធីយុទ្ធនាការគាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធឺណិត ក្រោមប្រធានបទ «រួមគ្នាលើកកម្ពស់ការសន្ទនា និងការអប់រំសុវត្ថិភាពកុមារ និងយុវជនក្នុងយុគសម័យឌីជីថល នៅវិទ្យាស្ថានបច្ចេកទេសកម្ពុជា(តិចណូ) ០១លើក។ |

| | |
|---|---|
| **ខេត្តសៀមរាប** | - គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំ ០៣លើក មានអ្នកចូលរួម **២៥៣**នាក់ ស្រី **១០៩**នាក់។<br>- ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ថ្នាក់ក្រុង-ស្រុក រៀបចំប្រជុំចំនួន **០៥**លើក អ្នកចូលរួម **១៣០**នាក់ ស្រី**៤៥**នាក់។<br>- តំណាងមន្ទីរអប់រំយុវជន និងកីឡា និងមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ បានចូលរួមកម្មវិធីយុទ្ធនាការគាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធឺណិត ក្រោមប្រធានបទ «រួមគ្នាលើកកម្ពស់ការសន្ទនា និងការអប់រំសុវត្ថិភាពកុមារ និងយុវជនក្នុងយុគសម័យឌីជីថល នៅវិទ្យាស្ថានបច្ចេកទេសកម្ពុជា(តិចណូ) ០១លើក។ |
| **ខេត្តបាត់ដំបង** | - **មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានចាត់តំណាងចូលរួម៖<br>◦ សម្របសម្រួលក្នុងវគ្គផ្សព្វផ្សាយស្តីពី សុវត្ថិភាពនៃការធ្វើចំណាកស្រុក ការការពារជំងឺអេដស៍ និងការទប់ស្កាត់ការប្រើប្រាស់សារធាតុញៀន ដល់ពលករដែលត្រឡប់មកពីថៃ ចំនួន **៧៦៥**នាក់ ស្រី**៣២០**នាក់ នៅមណ្ឌលទទួលពលករកំរៀង ដែលរៀបចំដោយអង្គការប្រតិបត្តិ ចំនួន០២លើក។<br>◦ ផ្សព្វផ្សាយស្តីពី ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព នីតិវិធីជ្រើសរើសបញ្ជូន និងគ្រប់គ្រងពលករទៅធ្វើការនៅក្រៅប្រទេស នៅស្រុកកំរៀង និងស្រុកបវេល មានអ្នកចូលរួម **១៣៧**នាក់ ស្រី **៦៧**នាក់ គាំទ្រថវិការដោយអង្គការអន្តរជាតិខាងការងារ (ILO) និងក្រុមហ៊ុនមហាចក្រឌីវេឡុបម៉ិន ឯ.ក។<br>◦ បានរៀបចំកិច្ចប្រជុំស្តីពីការចែករំលែកលិខិតបទដ្ឋានបទប្បញ្ញត្តិនិងរបាយការណ៍ថ្មីៗ ទាក់ទងនឹងការគ្រប់គ្រងទេសន្តរប្រវេសន៍ ក្រោមការគាំទ្រពីអង្គការអន្តរជាតិ (ILO) ដល់អាជ្ញាធរមូលដ្ឋាន។<br>◦ ប្រជុំជាមួយអង្គការដៃគូ ទីភ្នាក់ងារជ្រើសរើសឯកជន មានអ្នកចូលរួម **៤៤**នាក់ ស្រី**២២**នាក់ នៅសាលប្រជុំវិទ្យាស្ថានបច្ចេកវិទ្យាបាត់ដំបង។<br>- បានចូលរួមកម្មវិធីយុទ្ធនាការគាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធឺណិត ក្រោមប្រធានបទ «រួមគ្នាលើកកម្ពស់ការសន្ទនា និងការអប់រំសុវត្ថិភាពកុមារ និងយុវជនក្នុងយុគសម័យឌីជីថល នៅវិទ្យាស្ថានបច្ចេកទេសកម្ពុជា(តិចណូ) ០១លើក។<br>- បានចូលរួមប្រជុំជាមួយក្រុមការងារអន្តរក្រសួង (តំណាងក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងតំណាងអង្គការយូនីសេហ្វ) ដើម្បីពិនិត្យលទ្ធផល និងបញ្ហាប្រឈមក្នុងការសាកល្បងនីតិវិធីប្រតិបត្តិកិច្ចការពារកុមារ សម្រាប់ស្រុកបាណន់ និងក្រុងបាត់ដំបង ០១លើក។ |
| **ខេត្តកំពង់ធំ** | - លោកស្រី **លំ គន្ធារី** អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមប្រជុំតាមប្រព័ន្ធអនឡាញ ជាមួយអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងអង្គការ IJM ស្តីពី "លទ្ធផលដែលបានរកឃើញពីការសិក្សាពីបច្ចុប្បន្នភាពរបស់ពលករចំណាកស្រុកទាក់ទងនឹងស្ថានភាពការងារ និងជីវភាពរស់នៅតាមប្រទេសគោលដៅ"។<br>- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ស្ត្រីក្នុងវិស័យនគរបាលជាតិ នៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន មានអ្នកចូលរួម **២៣**នាក់ ស្រី**១៤**នាក់។ |
| **ខេត្តតាកែវ** | - សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អង្គការ UNICEF រៀបចំកិច្ចប្រជុំផ្សព្វផ្សាយ ផែនការកិច្ចការពារកុមារខេត្តតាកែវ (២០២៣-២០២៥) ០១លើក មានអ្នកចូលរួម **១១០**នាក់ ស្រី **៦៣**នាក់។<br>- ចូលរួមកិច្ចប្រជុំស្តីពីការតាមដានត្រួតពិនិត្យការគ្រប់គ្រងករណីតាមប្រព័ន្ធ Primero និងផ្ទៀងផ្ទាត់ទិន្នន័យអធិការកិច្ចកន្លែងថែទាំកុមារតាមប្រព័ន្ធអនឡាញ ០១លើក។ |
| **ខេត្តកំពង់ឆ្នាំង** | - ប្រធានលេខាធិការដ្ឋាន គជ បានដឹកនាំកិច្ចប្រជុំត្រួតពិនិត្យរបាយការណ៍លទ្ធផលអនុវត្តការងារប្រចាំខែ.ប.ខ. ឆ្នាំ២០២៣ ០១លើក។ |